ចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

===

## ៣_សារាចរណែនាំ

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០១

**សារាចរណែនាំ លេខ ០៨ សរណន**

**ស្តីពីការរៀបចំយុទ្ធនាការ "ផ្តល់ការគាំទ្រចំពោះកុមារ"**

---

ក្នុងគោលបំណងពង្រឹងពង្រីកសកម្មភាព សំដៅធ្វើអោយកុមារទទួលបាននូវសិទ្ធិកាន់តែល្អប្រសើរឡើងថែមទៀត និងដើម្បីចូលរួម "**ចលនាពិភពលោកដើម្បីកុមារ**" ដែលមានព្រឹត្តិការណ៍សំខាន់ៗដូចជាការពិនិត្យ ឡើងវិញនូវស្ថានភាពរបស់កុមារ ការវាយតំលៃលើការរីកចំរើនដែលបានអនុវត្តតាមកម្មវិធីអន្តរជាតិ ដើម្បីកុមារ ឆ្នាំ ១៩៩០ ការធ្វើយុទ្ធនាការផ្តល់ការគាំទ្រចំពោះកុមារ និងការប្រជុំអំពីកុមារជាបន្តបន្ទាប់ ហើយសម័យប្រជុំ ពិសេសអំពីកុមារនៃមហាសន្និបាតអង្គការសហប្រជាជាតិ ដែលនឹងប្រព្រឹត្តទៅក្នុងខែកញ្ញា ឆ្នាំ ២០០១ នាពេលខាងមុខ នៅទីក្រុងញូវយ៉ក ដោយមានប្រទេសហត្ថលេខីជាច្រើនចូលរួម ។

កន្លងមក ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ហើយត្រូវចូលរួមចំណែកក្នុងចលនាពិភពលោកដើម្បីកុមារ និងបង្កើនកិច្ចគាំទ្រដល់កុមារកម្ពុជា ដែលជាអ្នកបន្តវេនសំរាប់អនាគតនៃប្រទេសជាតិ ។ កាលពីថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍បើកយុទ្ធនាការ និងចុះហត្ថលេខាលើប័ណ្ណ "**ផ្តល់ការគាំទ្រចំពោះកុមារ**" ដោយបានអំពាវនាវដល់ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ បញ្ញាវ័ន្ត ព្រះសង្ឃ ប្រជាពលរដ្ឋ កុមារា និងកុមារី អោយចូលរួមយ៉ាងសកម្មក្នុងចលនា

ផ្តល់មតិ និងចុះហត្ថលេខាលើខិត្តប័ណ្ណ "**ផ្តល់ការគាំទ្រចំពោះកុមារ**" ព្រមទាំងចូលរួមសកម្មភាពផ្សេងៗទៀតសំរាប់កុមារ ។

ដើម្បីអនុវត្តតាមស្មារតីខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំដូចតទៅ :

**១-ការធ្វើយុទ្ធនាការ "ផ្តល់ការគាំទ្រចំពោះកុមារ"**

-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវរៀបចំយុទ្ធនាការ "**ផ្តល់ការគាំទ្រចំពោះកុមារ**" ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

-ក្រសួងអប់រំយុវជន និងកីឡា សហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវរៀបចំក្រុមលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ដើម្បីចូលរួមសកម្មភាពយុទ្ធនាការ ។

-ក្រសួងធម្មការ និងសាសនា ត្រូវចូលរួមសកម្មភាពយុទ្ធនាការដោយសុំហត្ថលេខាពីព្រះសង្ឃ ។

-អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ត្រូវចូលរួមសហការ និងគាំទ្រដល់សកម្មភាពយុទ្ធនាការនៅក្នុងមូលដ្ឋានរបស់ខ្លួន ។

-គ្រប់ក្រសួង-ស្ថាប័ន ត្រូវបំផុសចលនាដល់មន្ត្រីរាជការក្រោមឱវាទ ចូលរួមសកម្មភាពយុទ្ធនាការ និងចុះហត្ថលេខាលើខិត្តប័ណ្ណ "**ផ្តល់ការគាំទ្រចំពោះកុមារ**" ។

**២-ការធ្វើព្យុហយាត្រា**

-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សហការជាមួយក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងអប់រំយុវជន និងកីឡា ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងអង្គការក្រៅរដ្ឋាភិបាលនានា ត្រូវរៀបចំព្យុហយាត្រានៅវិមានឯករាជ្យនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ អោយបានយ៉ាងឱឡារិក អធិកអម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ។

**៣-ការធ្វើសេចក្តីរាយការណ៍**

-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវរៀបចំគណៈប្រតិភូ និងឯកសារដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា អំពីលទ្ធផលយុទ្ធនាការ "**ផ្តល់ការគាំទ្រចំពោះកុមារ**" និងសហការជាមួយអង្គការ យូនីសេហ្វ ដើម្បីបញ្ជូនលទ្ធផលបូកសរុបទៅទីក្រុងញូវយ៉ក ។

៤-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយសំភារៈ ថវិកា សំរាប់អនុវត្តយុទ្ធនាការនេះឱ្យបានទាន់ពេលវេលា ដើម្បីធានាការចាត់តាំងសមស្របតាមគោលបំណង និងសំណូមពរ ។

រាជរដ្ឋាភិបាល សូមអំពាវនាវដល់ អង្គការជាតិ-អន្តរជាតិ ផ្នែកឯកជន និងប្រជាពលរដ្ឋ សូមជួយឧបត្ថម្ភគាំទ្រដល់កម្មវិធីទាំងនេះអោយបានផុលផុស អធិកអធម ។

ទទួលបាននូវសារាចរណែនាំនេះ សូមឯកឧត្តមថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្ត ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

## III- ការងារបណ្ដាក្រសួង

### ១-និស្ដីការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០១

**ប្រកាសលេខ ៣២៩ ឧរថក១.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្ដេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល